# សិក្ខាសាលាស្តីពីការសិក្សាលើការតម្រឹមការិយាល័យពលរដ្ឋនិងក្រុមការងារគណនេយ្យខេត្ត

## ការវាយតម្លៃលើ៖
## “ការតម្រឹមឡើងវិញលើការងារការិយាល័យពលរដ្ឋ និង ប្រព័ន្ធក្រុមការងារគណនេយ្យភាពខេត្ត”

ថ្ងៃទី៤ ខែមេសា ឆ្នាំ២០១២

បង្ហាញដោយ៖ លោក ភីធើ ហ្គ្រាហាម និង អ៊ឹមសុភា

## ប្រវត្តិដើមនៃការសិក្សា

“គោលបំណងនៃគម្រោងDFGGគឺដើម្បីពង្រឹងការធ្វើឲ្យប្រសើរឡើងដល់អភិបាលកិច្ចល្អ នៅតាមបណ្តាក្រុង/ ស្រុក ក្នុងខេត្តនានានៃប្រទេស”

“ធនាគារពិភពលោកបានផ្តល់មូលនិធិគម្រោង DFGG ដែលក្នុងនោះមានគំនិតផ្តួចផ្តើមមួយក្នុងចំណោមនោះគឺ....ការពង្រីកការងារច្រកចេញចូលតែមួយ និង ការិយាល័យពលរដ្ឋនៅតាមបណ្តាក្រុង/ ស្រុកដែបានជ្រើសរើស”

“ ធនាគារពិភពលោក ក៏បានគាំទ្រការងារក្រុមគណនេយ្យភាពជាតិ និងខេត្តដែលមានបំណងធានានូវតម្លាភាព គណនេយ្យភាព និងប្រសិទ្ធិភាពប្រើប្រាស់ថវិការឃុំសង្កាត់ និងថវិការផ្សេងទៀតដែលស្ថិតក្រោមការគ្រប់គ្រងរបស់ **NCDDS”**

“ដើម្បីលើកអំពីបញ្ហាកើតមាននានា ការពិនិត្យឡើងវិញដំណាក់កាលពាក់កណ្តាលនៃគម្រោង **DFGG** បានប្រកាសរកការតម្រឹមការងារការិយាល័យពលរដ្ឋ និងក្រុមការងារគណនេយ្យភាពខេត្ត នៅក្នុងការតម្រឹមបន្ថែមទៀតក្នុងគម្រោង **IP3**”

“គោលបំណងនៃការសិក្សា (សិក្សាដោយទីប្រឹក្សា)គឺដើម្បីរកមធ្យោបាយដែលអាចធ្វើឲ្យការិយាល័យពលរដ្ឋអាចធ្វើការតម្រឹមបានល្អជាមួយក្រុមការងារគណនេយ្យភាពខេត្ត ដោយស្ថិក្នុងបរិបទនៃគម្រោង **IP3.”**

## ហេតុអ្វីត្រូវតម្រឹមឡើង?

ទាមទារឲ្យមានការចាប់អារម្មណ៍ក្នុងរបាយការណ៍ ចុះបន្ទាប់ពីឆ្នាំ២០១១បន្ទាប់ពីបានការពិនិត្យ Révue of DFGG Project

ធ្វើឲ្យប្រសើរឡើងដល់ការដោះស្រាយបណ្ដឹងនៅថ្នាក់ក្រោមខេត្តគ្រប់កំរិត

មានកំរិតខុសៗគ្នាក្នុងប្រតិបត្តិការក្នុង ក្រុមការងារគណនេយ្យភាពខេត្ត និងការិយាល័យពលរដ្ឋ

ក្រុមការងារគណនេយ្យភាព កើតមានមុនការអភិវឌ្ឍរដ្ឋបាលស្រុក ឬ ការិយាល័យពលរដ្ឋ

មានការទទួលខុសត្រូវជាន់គ្នា (ដូចមានការកត់សំគាល់ក្នុងរបាយការណ៍ត្រួតពិនិត្យ”

មានការងារជាន់គ្នា(ដូចមានសំគាល់ក្នុងរបាយការណ៍ត្រួតពិនិត្យប្រចាំឆមាស់)”

មានការយល់ច្រលំលើមុខនាក្នុងការគឹតគូក្នុងចិត្ត

ការចំណាយធនធានតិចតែមានផលច្រើន

---

តើយើងចង់មានន័យដូចម្ដេចលើពាក្យ “ការតម្រឹមឡើងវិញឬការតម្រឹម?” នោះគឺការដឹកនាំស្ថាប័ននីមួយៗឲ្យចូលក្នុងព្រំដែនតែមួយដើម្បីធ្វើឲ្យការទទួលខុសត្រូវជាច្រើនអាចដាក់ចូលគ្នាបាន និងមានប្រសិទ្ធិផល”

ការណ៍នេះមិនមែនមានន័យថា “ធ្វើសហរមាណកម្មការិយាល័យពលរដ្ឋ និងក្រុមការងារគណនេយ្យភាពខេត្តជាអង្គការមួយនោះទេ” ទោះបីជាមានការពិចារណាជម្រើសនេះរួចក៏ដោយ។

## គោលដៅ

គឺដើម្បីធ្វើឲ្យមានជម្រើសនានារួចជាស្រេច ដើម្បីតម្រឹមឡើងវិញនូវប្រព័ន្ធការងារការិយាល័យពលរដ្ឋ នឹងដើម្បីពិនិត្យលើគុណសម្បត្ត និងគុណវិបត្តិនីមួយក្នុងការបញ្ចេញទស្សនៈដើម្បីផ្តល់អនុសាសន៍ដែលអាចទទួលយកបានក្នុងផែនការសកម្មភាព។

## កត្តាដែលត្រូវពិចារណា

កត្តាទាំងអស់នេះបានមកពីទស្សនៈនានារបស់មន្ត្រីនានាក្នុងពេលជួបសន្ទនានៅថ្នាក់ខេត្ត ស្រុក និងរបាយការណ៍នានា ការវិភាគទាំងឡាយ ដែលបានបោះពុម្ពផ្សាយកន្លងមក

## ការិយាល័យច្រកចេញចូលតែមួយ (OWSO)

* មានការកើនឡើងនូវការជឿជាក់ និងការពេញចិត្តរបស់សាធារណជនលើសេវាកម្មផ្តល់ដោយដោយការិយាល័យច្រកចេញចូលតែមួយ

* មានថយចុះតម្រូវការក្នុងការដោះស្រាយបណ្តឹងបណ្តាលមកពីការខកខានបំពេញការងារដោយបុគ្គលិក និងនីតិវិធីក្នុងការងារការិយាល័យ ច្រកចេញចូលតែមួយ

* មានការធ្វើប្រតិភូកម្មមួយចំនួនពីក្រសួង/ មន្ទី/ មកការងារការិយាល័យ ច្រកចេញចូលតែមួយ។ស្ថាប័នខ្លះកំពុងធ្វើការពិចារណា។

*ការវាយតម្លៃគម្រោង MTR បានលទ្ធផលគួរជាទីពេញចិត្ត

*យ៉ាងហោចណាស់ក៏មានចំណូលលើសចំណាយសម្រាប់ក្រុងបាត់ដំបង និងសៀមរាប

## ការិយាល័យពលរដ្ឋ(DO)

* ត្រូវបានបង្កើតជាមួយការិយាល័យច្រកចេញចូលតែមួយ ប៉ុន្តែមានឯករាជ្យភាពរបស់ខ្លួន
* ពុំមានបណ្តាញត្រួតពិនិត្យមើលការិយាល័យពលរដ្ឋ
* អណត្តិការងារមិនបានហាមឃាត់ គ្រាន់តែទទួលបន្ទុកមើលការងារការិយាល័យច្រកចេញចូលតែមួយ
* ទទួលបានការបណ្តុះបណ្តាលនិងការអភិវឌ្ឍជំនាញដោះស្រាយបណ្តឹង
* មិនមានបន្ទុកខ្លាំងហួសហេតុលើតម្រូវការដោះស្រាយបណ្តឹង
* ធ្វើការបញ្ជូនបន្តនូវអំណាចដល់អភិបាលស្រុក/ក្រុង មន្ទី ។ល។
* ទទួលបានទំនុកចិត្តពីសាធារណជន
* ដោះស្រាយបញ្ហាបានលឿន
* ការងារត្រូវបានត្រួតពិនិត្យដោយក្រុមប្រឹក្សាស្រុក/ក្រុង
* បានបំពេញតួនាទីនិងសកម្មក្នុងការផ្សព្វផ្សាយព័ត៌មាន/ អបរំមហាជន
* ត្រូវបានគេមើលឃើញថាជាយន្តការគណនេយ្យភាពដ៏ “មានហេតុផល”

## ក្រុមការងារគណនេយ្យភាពខេត្ត(PAWG)

* ក្រុមការងារគណនេយ្យភាពត្រូវបានបង្កើតនៅតាមបណ្តាខេត្តនីមួយៗ
* ប្រអប់គណនេយ្យភាពត្រូវបានដាក់នៅពាសពេញប្រទេស នៅតាមទីតាំងល្អៗ ដើម្បីទទួលបណ្តឹង
* នីតិវិធីនានាសម្រាប់ដោះស្រាយបណ្តឹងត្រូវបានបង្កើត
* ការស៊ើបអង្កេតបានធ្វើជាច្រើនរឿង
* ដំណើការដោះស្រាយ/ ស៊ើបអង្កេតមានសភាពយឺតយ៉ាវ
* សាធារណជនមិនទាន់យល់ច្បាស់ពីអណត្តិការងាររបស់ក្រុមការងារគណនេយ្យភាពខេត្ត
* ស្ថាប័ននេះត្រូវបានគ្រប់គ្រង និងគាំទ្រដោយអភិបាលខេត្ត
* មានគណនេយ្យភាពក្នុងការបញ្ជូនសំណុំរឿងមកមន្ទីពាក់ព័ន្ធ
* ត្រូវបានគេមើលឃើញថាជាយន្តការគណនេយ្យភាពប្រកបដោយ″ការរុញច្រាន″

## រដ្ឋបាលក្រសួង និងមន្ទីនានា

* តំណាងស្ថាប័នមួយចំនួនបានធ្វើប្រតិភូកម្មរួចហើយមកថ្នាក់ស្រុក/ ក្រុង
* មានគម្រោងធ្វើប្រតិភូកម្មបន្ថែមទៀត
* រក្សាយន្តការបណ្តឹងជាបុគ្គល់
* ស្ថិតក្រោមការត្រួតពិនិត្យរបស់អភិបាលស្រុក/ក្រុង

## អង្គការមិនមែនរដ្ឋាភិបាល(NGOs)

* គាំទ្រការងារក្រុមគណនេយ្យភាពខេត្ត ប៉ុន្តែមិនបានពាក់ព័ន្ធច្រើនក្នុងការងារការិយាល័យពលរដ្ឋ

* ចូលរួមចំណែកក្នុងការផ្សព្វផ្សាយព័ត៌មាន

* ជួយក្នុងការដោះស្រាយបណ្តឹងតវ៉ា

## បណ្តឹងតវ៉ានិងដើមបណ្តឹង

*សារសំខាន់លើការសម្ងាត់នៃបណ្តឹងតវ៉ា

*ដើមបណ្តឹងអនាមិកមិនបណ្តាលឲ្យមានបញ្ហាក្នុងការស៊ើបអង្កេតដោយការិយាល័យពលរដ្ឋ ឬក្រុមការងារគណនេយ្យភាពខេត្តទេ

* ភាពស្រដៀងគ្នា /បណ្តឹងស្ទួន

## ស្ថាប័នឃុំសង្កាត់

* ក្រុមប្រឹក្សាឃុំសង្កាត់ និងមេឃុំ/ ចៅសង្កាត់ ប្រធានភូមិអាចទទួល និងដោះស្រាយបណ្ដឹងតវ៉ាមួយចំនួនមិនផ្លូវការ

* ទំនាក់ទំនងរវាងការិយាល័យពលរដ្ឋ និងការិយាល័យច្រកចេញចូលតែមួយ និង ក្រុមការងារគណនេយ្យភាពខេត្តនៅមានកំរិត

## ផ្នែកហិរញ្ញវត្ថុ

* ថវិការចំណាយអាទិភាព (POC) មានសារៈសំខាន់សម្រាប់និរន្តភាពការងារទាំងពីរស្ថាប័ន៖ ក្រុមការងារគណនេយ្យភាពខេត្ត និងការិយាល័យពលរដ្ឋ

* កង្វះខាតថវិការនៅតែជាបញ្ហាចម្បងប៉ះពាល់ការបំពេញការងាររបស់ក្រុមការងារគណនេយ្យភាពខេត្ត

## កម្មវិធីជាតិប្រឆាំងអំពើពុករលួយ

*មិនមានភាពសហការគ្នារវាងទីភ្នាក់ងាររដ្ឋបាលមូល ដ្ឋាន និងអង្គភាពប្រឆាំងអំពើពុករលួយ

* អង្គភាពប្រឆាំងអំពើពុករលួយអាចប្រើប្រាស់ស្ថាប័នទាំងពីរ៖ក្រុមការងារគណនេយ្យភាពខេត្ត និង ការិយាល័យច្រកចេញចូលតែមួយសម្រាប់ធ្វើការងារ ផ្សព្វផ្សាយ/ អបរំ/ បង្ការ

* ក្រុមការងារគណនេយ្យភាពខេត្តមិនបានបញ្ជូនសម ណុំរឿងទៅអង្គភាពប្រឆាំងអំពើពុករលួយ

## អណត្តិការងារ

* អណត្តិដើមរបស់ក្រុមការងារគណនេយ្យភាពផ្តោតត្រឹមថវិការឃុំសង្កាត់ ប៉ុន្តែបានពង្រីកវិសាលភាពបន្ថែមទៀត

* អណត្តិការងារការិយាល័យពលរដ្ឋពាក់ពន្ធ័នឹងសេវាកម្ម ការិយាល័យច្រកចេញចូលតែមួយ បច្ចុប្បន្ននេះមានពង្រីកសេវាកម្ម និងបង្កើនចំនួនបុគ្គលិក

## ព្រំដែនគណនេយ្យភាព

* ការិយាល័យពលរដ្ឋមានគណនេយ្យភាពចំពោះក្រុមប្រឹក្សាស្រុក (លើកកម្ពស់ការអភិវឌ្ឍលទ្ធិប្រជាធិបតេយ្យ) ចំណែកក្រុមការងារគណនេយ្យភាពខេត្តមានគណនេយ្យភាពចំពោះអភិបាលនៃគណៈអភិបាលខេត្ត

* នីតិវិធីនៃការជ្រើសរើសក៏មានភាពខុសគ្នាដែរ

## ការទទួលបានព័ត៌មាន

ការិយាល័យពលរដ្ឋ នឹងដើរតួរសំខាន់ថែមទៀតនៅពេលដែលមជ្ឈមណ្ឌលព័ត៌មានពលរដ្ឋត្រូវបានបង្កើតឡើង(ការរៀបចំកំពុងធ្វើសម្រាប់បង្កើតក្នុងឆ្នាំនេះ)




## ជម្រើសបើកចំហរនានា

## ជម្រើសទី១




បញ្ចូលការិយាល័យពលរដ្ឋ និងក្រុមការងារគណនេយ្យភាពខេត្តជាស្ថាប័នមួយដែលមានមុខងារទទួលដោះស្រាយពាក្យបណ្តឹងពាក់ព័ន្ធនិងសេវាកម្មការិយាល័យច្រកចេញចូលតែមួយ និងថវិការឃុំសង្កាត់ (រួមទាំងថវិការស្រុកក្រុង ដែលត្រូវអនុវត្តក្នុងឆ្នាំ២០១៣)។

**គុណសម្បត្តិ**
- ការងារនេះស្រួលណាស់។

**គុណវិបត្តិ**
- ធ្វើឲ្យចុះខ្សោយអត្តសញ្ញាណការិយាល័យពលរដ្ឋ (Ombudsman)និងការដោះស្រាយបណ្តឹងរបៀបសម្របសម្រួល។
- ដកហូតសមត្ថភាពការងារគណនេយ្យភាពរបស់ការិយាល័យពលរដ្ឋចេញពីថ្នាក់ស្រុក មកនៅត្រឹមថ្នាក់ខេត្ត។
- ធ្វើឲ្យមានការចុះខ្សោយដល់ការបង្កើតឲ្យមានភាពត្រឹមត្រូវនូវប្រព័ន្ធគណនេយ្យភាពថ្នាក់ក្រោមជាតិ សមត្ថភាពក្នុងការស៊ើបអង្កេតអំពើពុករលួយដែល បច្ចុប្បន្ននេះស្ថិតក្នុងដៃក្រុមការងារគណនេយ្យភាពខេត្ត។
- ផ្តល់មុខងារដល់ការិយាល័យពលរដ្ឋជាស្ថាប័នអនុវត្តច្បាប់ដែលការណ៍នេះខុសពីមុខងារនិងអត្តសញ្ញាណការិយាល័យពលរដ្ឋ។
- ធ្វើឲ្យមានការយល់ច្រលំលើសម្ព័ន្ធភាពសេវាផ្តល់ជូន (ការិយាល័យច្រកចេញចូលតែមួយ/ការិយាល័យពលរដ្ឋ) នឹង(ក្រុមការងារគណនេយ្យភាព) ការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ និងការដាក់ពិន័យចំពោះការបំពានក្រមសីលធម៌។
- មិនស្របតាមគោលនយោបាយស្វ័យភាពនិងការផ្តល់វិមជ្ឈការ។
- តម្រូវឲ្យមានបុគ្គលិកច្រើនធ្វើការងារនេះ។

## ជម្រើសទី២

PAWG — DO

ពង្រីក និងពង្រឹងចំនួនសេវាកម្មនានា (ដែលផ្តល់ដោយការិយាល័យច្រកចេញចូលតែមួយ) ដោយមានការត្រួតពិនិត្យមើលដោយការិយាល័យពលរដ្ឋ។ កាត់បន្ថយការទទួលខុសត្រូវរបស់ក្រុមការងារគណនេយ្យភាពខេត្ត ដូចមានចែងក្នុងអណត្តិដំបូងរបស់ខ្លួន (អាចធ្វើការបញ្ជាក់ច្បាស់លាស់បាន)។

គុណសម្បត្តិ

- ប្រើឲ្យអស់លទ្ធភាពនៃការប្រើប្រាស់ដំណើការដោះស្រាយរបៀប"ទន់ភ្លន់ជាង" នៅក្រប់កំរិត។
- សាធារណជនគាំទ្រការពង្រីកសេវាកម្មការិយាល័យច្រកចេញចូលតែមួយ។
- មានដំណោះស្រាយលឿនជាង។
- ធ្វើឲ្យមានជំនឿជឿជាក់ពីសំណាក់អ្នកប្តឹងតវ៉ា។
- រក្សាបានឯករាជ្យភាពនៃមុខងារការត្រួតពិនិត្យតាមរយៈសមាជិកការិយាល័យពលរដ្ឋដែលជ្រើសរើសតាមការបោះឆ្នោត។
- បង្កើតឲ្យមានរូបភាពប្រសើរឡើងលើឆាកអន្តរជាតិ។
- ប្រើប្រាស់ប្រយោជន៍ពីស្ថាប័ននានាដែលមានស្រាប់និងលើកកម្ពស់ការយល់ដឹងរបស់សាធារណជន។

គុណវិបត្តិ

- កង្វះខាតមុខងារគណនេយ្យភាព "ផ្លូវការ"។
- កាត់បន្ថយអំណាចក្រុមការងារគណនេយ្យភាពខេត្តដូចនៅក្នុងអណត្តិដើមនៃមូលនិធិឃុំសង្កាត់។

## ជម្រើសទី២

PAWG — DO

កែសម្រួលអណត្តិការងារក្រុមការងារគណនេយ្យភាពខេត្ត និងការិយាល័យពលរដ្ឋដែលទទួលស្គាល់ភាពខុសគ្នា ទុកនូវអ្វីដែលមានស្រាប់ក្នុងពេលបច្ចុប្បន្ន។ក្រុមការងារគណនេយ្យភាពខេត្តនឹងក្លាយជាអង្គាធម៌ប្រឆាំងអំពើពុករលួយនៅថ្នាក់ខេត្ត និងថ្នាក់ក្រោម ដើម្បីទទួលនិងស៊ើបអង្កេតពាក្យបណ្តឹងពាក់ព័ន្ធអំពើពុករលួយ និងអនុវត្តខុសផ្នែកហិរញ្ញវត្ថុ។ អណត្តិរបស់ការិយាល័យពលរដ្ឋនឹងរួមបញ្ចូលការអនុវត្តខុសក្រមសីលធម៌បុគ្គលិកនិងការមិនអនុវត្តតាមនីតិវិធីនានារបស់មន្ទីនានានៅថ្នាក់ស្រុក។

គុណសម្បត្តិ

- ប្រើប្រាស់អស់លទ្ធភាពនូវស្ថាប័នដែលមានស្រាប់។
- កាត្តបន្ថយពេលវេលាចំនាយលើការស៊ើបអង្កេតរបស់ក្រុមការងារគណនេយ្យភាពខេត្ត។
- ពង្រឹងមុខងារផ្លូវការ(ការអនុវត្តច្បាប់ និងការប្រឆាំងអំពើពុករលួយ)របស់ក្រុមការងារគណនេយ្យភាពខេត្ត។
- ពង្រីកអំណាចរបស់ការិយាល័យពលរដ្ឋ និងធ្វើឲ្យមានអព្យាក្រិតភាពកាន់តែធំឡើង ក្នុងការដោះស្រាយបណ្តឹងគ្រប់មន្ទីពាក់ព័ន្ធ។
- កាត់បន្ថយការចំណាយលើក្រុមការងារគណនេយ្យភាពខេត្ត។

គុណវិបត្តិ

- តម្រូវឲ្យមានថវិការបន្ថែមទៀតសម្រាប់ការិយាល័យពលរដ្ឋនិងបុគ្គលិក។
- អាចតម្រូវឲ្យធ្វើការកែសម្រួលឡើងវិញលើការទទួលខុសត្រូវរបស់ការិយាល័យច្រកចេញចូលតែមួយ។

## ជម្រើសទី២




ដាក់មន្ត្រីការិយាល័យពលរដ្ឋជាសមាជិកក្រុមការងារគណនេយ្យភាពខេត្ត។ ករណីនេះតម្រូវឲ្យមានការធានាលើការងារសម្រាំងពាក្យបណ្តឹងទទួលបាននៅថ្នាក់កណ្តាលរួមគ្នា ដើម្បីថានានូវការបញ្ជូនដោះស្រាយសមស្របទាន់ពេលវេលា។ ជម្រើសនេះជួយធានាការទំនាក់ទំនងគ្នាលើការងារ និងការផ្សព្វផ្សាយផ្លូវការរួមគ្នា ដោយចៀសវាងធ្វើការងារជាន់គ្នា។

គុណសម្បត្តិ
- បង្កើនល្បឿននៃការដោះស្រាយពាក្យបណ្តឹង។
- ធ្វើឲ្យមានភាពសាមញ្ញដោយមានប្រអប់សំបុត្រតែមួយសម្រាប់ឲ្យសាធារណជនងាយយល់ដឹង។
-ពង្រឹងគោលនយោបាយនិងវិន័យ។
- បញ្ជូនបណ្តឹងទាំងឡាយណាដែលសាមញ្ញដែលមិនត្រូវស្ថិតក្នុងអណត្តិត្រូវដោះស្រាយ។

គុណវិបត្តិ
- មានការិយាល័យពលរដ្ឋច្រើនពេកនៅក្នុងក្រុមការងារគណនេយ្យភាពខេត្ត នៅតាមបណ្តាខេត្តមួយចំនួននិងរាជធានីភ្នំពេញ។
- បង្កើនទំហំការងាររបស់ការិយាល័យពលរដ្ឋ។
- អាចមិនមានការទុកចិត្តនិងទទួលបានជំនឿពីសាធារណជន។ ប្រសិនជាគ្មានការធ្វើឲ្យប្រសើរឡើងក្នុងការងារពន្យល់ផ្សព្វផ្សាយ។

## អនុសាសន៍សម្រាប់អនុវត្តពេលខាងមុខ

# ១. កែសម្រួលអណត្តិការងារការិយាល័យពលរដ្ឋនិងក្រុមការងារគណនេយ្យភាពខេត្តដូចមានក្នុងជម្រើសទី៣។

## អនុសាសន៍សម្រាប់អនុវត្តពេលខាងមុខ

២. ពង្រីកសេវាការិយាល័យច្រកចេញចូលតែមួយដូចក្នុងជម្រើសទី២។

## អនុសាសន៍សម្រាប់អនុវត្តពេលខាងមុខ

៣. ពង្រីកសមាជិកភាពក្រុមការងារគណនេយ្យភាពខេត្ត និងការិយាល័យពលរដ្ឋ ដូចក្នុងជម្រើសទី៤។

## អនុសាសន៍សម្រាប់អនុវត្តពេលខាងមុខ

៤.គ្រួតពិនិត្យមើលឡើងវិញជុំវិញគណនេយ្យភាពការងារក្រុមការងារគណនេយ្យភាពខេត្ត (ចំពោះក្រុមប្រឹក្សាខេត្ត)។

## អនុសាសន៍សម្រាប់អនុវត្តពេលខាងមុខ

៥. ធ្វើការផ្សព្វផ្សាយឲ្យបានខ្លាំងក្លា និងការអប់រំមហាជនអំពីការប្រកាសស្តីពីការភ្ជាប់ការងារជាមួយគ្នានេះ។

## អនុសាសន៍សម្រាប់អនុវត្តពេលខាងមុខ

៦. ពិចារណាលើការពង្រីកការិយាល័យពលរដ្ឋ ឡើងដល់ថ្នាក់ជាតិ។

## អនុសាសន៍សម្រាប់អនុវត្ត

៧. ពិនិត្យឡើងវិញអំពីគោលនយោបាយដោះស្រាយបណ្តឹងថ្នាក់ជាតិ និងយន្តការនានា។

សូមអរគុណចំពោះការចូលរួមនិងស្តាប់

សូមសួរ ប្រសិនបើមានសំនួរ/ យោបល់/ អនុសាសន៍